ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

# សេចក្តីជូនព័ត៌មាន

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមជូនព័ត៌មានថា បន្ទាប់ពីមានហេតុការណ៍នៃការផ្ទុះ នៅក្នុងរថភ្លើងក្រោមដី ក្នុងទីក្រុង St. Petersburg កាលពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ នៅម៉ោង ១៤:៤០នាទី (ម៉ោងនៅទីក្រុង St. Petersburg) ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសហព័ន្ធរុស្ស៊ី បានទាក់ទងជាមួយសមាគមនិស្សិតកម្ពុជាប្រចាំនៅទីក្រុងនោះ ដើម្បីស្វែងយល់ពីសភាពការណ៍របស់និស្សិតយើង។

តាមរបាយការណ៍ទទួលបានពីស្ថានឯកអគ្គរាជទូត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមបញ្ជាក់ថា ពុំមានពលរដ្ឋ/និស្សិតខ្មែរណាម្នាក់ស្ថិតក្នុងចំណោមជនរងគ្រោះក្នុងហេតុការណ៍ផ្ទុះនេះឡើយ។

ភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៧

ជុំ សុន្ទរី
អ្នកនាំពាក្យ
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ